# ឈ

**ឈ** ព្យញ្ជនៈ ទី ៤ ក្នុងវគ្គទី ២ ជាគោសោសៈ មានសំឡេងកើតក្នុងពិតាន ពីត្រង់ក្រអូមមាត់ ។ ជាអឃោស-ឃោសៈ, ខាងសំស្ក្រឹតនិងបាលីមានសំឡេងជា *ឆ្ហ:* ។

**ឈប** *កិ.* សម្ដីពោលបន្លំសើច ក្លាយមកពីពាក្យ *ឈប់* ជាពាក្យប្រែកបញ្ច្រាសបុរសទាំងមានគោជាដើម ឲ្យឈប់ ឲ្យបង្អង់ តាមសញ្ញាដែលបានបង្គាប់ ដែលធ្លាប់ប្រើប្រាស់មក, ដោយសេចក្ដីច្បាស់ថា *ឯងឈប់!* ឬថា *ឈប់!* ។

**ឈប់** *កិ.* បង្អង់នៅស្ងៀម, លើកលែងធ្វើ; លែងប្រព្រឹត្ត: *កំឈប់រៀនហើយ, ឈប់សិន ចាំខ្ញុំផង!*

**ឈម** *កិ.* ឆ្លោះមុខរកគ្នា, សម្លក់ ឬសម្លឹងឆ្លោះទៅរកអ្វីមួយ: *កុំឈមកុំឈរជិត ក្រែងមិនគាប់ចិត្តគេ កុំល្បងល្បួងនោះណា ត្រូវឲ្យចាំឲ្យដឹងពេញ* (សាស្ត្រច្បាប់ប្រុស) ។

**ឈរ** *កិ.* ឋិតនៅពេញជំហរ ជើងជាន់ត្រង់, ជាឈ្មោះឥរិយាបថមួយ ក្នុងឥរិយាបថទាំង ៤ គឺ *ដើរ, ឈរ, អង្គុយ, ដេក* ។ ស្ថិតនៅ, នៅស្ថិតស្ថេរ: *កជការត្រូវចាត់ចែក... ឲ្យនៅឈរនៅក្រៅស្ថាប័នទៀត; ខ្ញុំបានឈរធ្វើកិច្ចការនេះអស់រយៈពេលច្រើនឆ្នាំ នៅក្នុងក្រសួងនេះ អស់ ៤ ឆ្នាំ* ។ នៅត្រង់មិនទៀងទាត់, មិនព្រាលប្រើមិនរឹងឡើង (ដំរី): *ដំរីឈរឲ្យមើលយូរណាស់ មិនដឹងគេត្រូវមើលគ្នា* ។ គុ. ឬ ន. អក្សរដែលមានឆ្អឹងត្រង់: *អក្សរឈរ* ។

**ឈាន** ១ *កិ.* លើកជើងដើរ, យាងសាចំងឈានធំហាន ទៅ: *ឈានដើរដើរ* ។

**ឈាន** ២ *ន.* (បា.; សំ. *ធ្យាន*) ការសម្ងំអារម្មណ៍ដែលជាឧបចារសមាធិ : *ចម្រើនឈាន, ចូលឈាន;* ឈានមាន ៤ ថ្នាក់ គឺថ្នាក់ទី ១ ហៅ *បឋមជ្ឈាន* មានអង្គ ៥ គឺ ១- *វិតក្កៈ* សេចក្ដីនឹកសំដៅឆ្ពោះទៅរកអារម្មណ៍ដែលកំពុងកាន់; ២- *វិចារៈ* សេចក្ដីពិចារណាអារម្មណ៍ដែលកំពុងកាន់; ៣- *បីតិ* សេចក្ដីឆ្អែតចិត្ត; ៤- *សុខៈ* សេចក្ដីសប្បាយ



ក្នុងចិត្ត; ៥- *ឯកគ្គតា* ដំណើរមូលចិត្តស្ងប់នៅក្នុងអារម្មណ៍តែមួយ (អង្គទាំង ៥ នេះ សំដៅចំពោះតែអារម្មណ៍ដែលស្ងប់ស្ងាត់ពោលគឺកម្មដ្ឋាន); ថ្នាក់ទី ២ ហៅ *ទុតិយជ្ឈាន* មានអង្គ ៣ គឺលះ *វិតក្កៈ* និង *វិចារៈ* ចេញ នៅសល់តែ *បីតិ* និង *សុខៈ* ដែលកើតជាប់មកអំពីសមាធិរបស់បឋមជ្ឈាន ជា ៣ នឹង *ឯកគ្គតា;* ថ្នាក់ទី ៣ ហៅ *តតិយជ្ឈាន* មានអង្គ ២ គឺលះ *បីតិ* ចេញ នៅសល់តែ *សុខៈ* និង *ឯកគ្គតា;* ថ្នាក់ទី ៤ ហៅ *ចតុត្ថជ្ឈាន* មានអង្គ ២ ដែរ លះ *សុខៈ* ចេញ ចិត្តក្លាយទៅជា *ឧបេក្ខា* គឺព្រងើយព្រងើយ ជា ២ នឹង *ឯកគ្គតា* ។ ឈានទាំង ៤ ថ្នាក់នេះ ហៅថា *រូបជ្ឈាន* មានរូបធម៌ជាអារម្មណ៍កប់បញ្ចូលក្នុងរូបាវចរភូមិ ។ បុគ្គលអ្នកចម្រើនភាវនា បានសម្រេចផ្លូវឈាន សូម្បីត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ក៏ជួបប្រទះសេចក្ដីសុខសប្បាយខ្លាំង ផ្ទាល់ពីសាមញ្ញសេចក្ដីអ្វីៗ ទាំងអស់ (ម. ព. *រូបជ្ឈាន, រូបធម៌, រូបាវចរភូមិ, សមាធិ, កម្មដ្ឋានស-មាធិ, អារម្មណ៍* ផង) ។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃទៀត អ. ថា. ឈានៈ ដូចជា *ឈានចិត្ត* (—ចិត) ចិត្តដែលបានសម្រេចឈាន ។ *ឈានផល* (—ផល់) ផលរបស់ឈាន, សេចក្ដីសម្រេចប្រយោជន៍ដែលកើតអំពីឈាន ។ *ឈានពល* (—ពល់) កម្លាំងនៃឈាន ។ *ឈានសុខ* (—សុក) សុខដែលកើតអំពីឈាន ។ *ឈានឫទ្ធិ* (—រឹត; បា. *ឈាន + ឥទ្ធិ;* សំ. *ធ្យាន + ឫទ្ធិ*) ឫទ្ធិនៃឈាន, ឫទ្ធិដែលកើតអំពីឈាន ។ *ឈានានុភាព* (—ភាប; បា. *ឈាន + អានុភាវ*) អានុភាព, អំណាច, តេជះនៃឈាន ។ល។

**ឈាន** — (មើលក្នុងពាក្យ *ឈាន* ) ។

**ឈាបនកិច្ច** (ឈាប៉ៈន៉ៈកិច) *ន.* (បា.) ការដុតសាកសព, ពាក្យនេះ សម្រាប់ប្រើជាសាធារណៈ មិនចំពោះបុគ្គល ។ មានន័យឲ្យប្រើតាមលំដាប់ជាន់ខ្ពស់, កណ្ដាល, ទាបផ្សេងៗគឺ សម្រាប់ព្រះបរមសពនៃព្រះមហាក្សត្រ, សម្ដេចព្រះរាជជននី, សម្ដេចព្រះអគ្គមហេសី, ព្រះសពសម្ដេចព្រះមហាសង្ឃរាជ, ព្រះអង្គម្ចាស់, អ្នកអង្គម្ចាស់ ហៅថា *ថ្វាយព្រះភ្លើង;* សម្រាប់សេនាបតីនិងមន្ត្រីជាន់ខ្ពស់ឬស្ត្រីប្រជាជនអ្នកមានកេរ្តិ៍ឈ្មោះ ហៅថា *រំលាយសព;* សម្រាប់បព្វជិតជាន់ខ្ពស់ ហៅថា *បូជា* ឬ *បូជាសព;* សម្រាប់ស្ត្រីប្រជាជាន់ខ្ពស់ ហៅថា *រំលាយ-រូប* ឬ *ធ្វើឈាបនកិច្ច;* សម្រាប់ជនសាធារណៈ ហៅថា *ដុត* ឬ *ដុតខ្មោច* ។

**ឈាបនដ្ឋាន** (ឈា-ប៉ៈន៉ាត-ឋាន) *ន.* (បា.) ទីសម្រាប់ធ្វើឈាបនកិច្ច, កន្លែងរំលាយសាកសព : *គេច្រើនកសាងឈាបនដ្ឋានជាសាធារណៈ នៅក្នុងវត្ត ឬក្នុងទីក្បែរវត្ត* ។

**ឈាម** *ន.* អាការៈ៣ (ធាតុទឹក) សម្បុរក្រហម ផ្សំ-ផ្សាយសព្វសរសៃក្នុងសពាង្គកាយ ។

**ឈៅ** គុ. ឬ កិ. វិ. ដែលរង្គើល, ខ្ទាយៗ, ល្ហោះៗ, ឬយឺតមួយកាល : *ស្ងួតឈៅ, សំងួតឈៅៗ, ទៅមកឈៅ* (ប្រើតាមទម្លាប់ស្រុក) ។

**ឈឹង** ន. ឈ្មោះគ្រឿងភ្លេងមួយប្រភេទក្នុងវង់ភ្លេងខ្មែរ : *ភ្លេងខ្មែរខ្វះឈឹង មិនសូវពីរោះ* ។

**ឈឹង** ១ គុ. ស្ងាត់ស្ងៀមស្ងប់, ស្ងប់ស្ងាត់, ស្ងៀម, ស្ងឹង : *ស្ងាត់ឈឹង, ស្ងប់ឈឹង, ថ្ងាត់ងាត់ឈឹង* ។

**ឈឹង** ២ ន. (ចិ.) ក្អមមានសណ្ឋានស្រដៀងឬប្រេង : *ដាក់ម្ហូបទុកលើឈឹង* ។

**ឈឹប** ឧ. សូរសំឡេងឮដោយទាក់ចិត្តឬប្លែកជាដើម : *តាក់ឈឹប ! ស្ងូរឈឹប !*

**ឈឺ** គុ. ដែលមានជំងឺ ។ កិ. ចាប់ជំងឺ, ទទួលរងជំងឺ ។ *ឈឺចិត្ត* ក្ដៅចិត្តហាក់ដូចជាកើតចាប់ឈឺផ្សា ។

**ឈឺឆ្អាល** កិ. យកអាសា, ជួយធ្វើកិច្ចការ, ជួយដោះទុក្ខធុរៈផ្សេងៗ : *ត្រូវជួយឈឺឆ្អាលគ្នាផង* ។

**ឈុត** ន. (ស. ឈុត អ.ច. ឈុត) ពាក្យសម្រាប់ប្រើហៅរបស់ដែលប្រមូលរួមចូលជាពួកមួយ, ជា ១ គ្រឿង : *វែន ១ ឈុត, ចាន ១ ឈុត* ។ រឿងមួយៗ ឬសង្កាត់រឿងមួយៗ : *ល្ខោនលេងរឿង ១ ឈុត, ឈុតទី ១, ឈុតទី ២* ។

**ឈូ** ឧ. សូរសំឡេងទឹកហូរខ្លាំងឬសំឡេងកញ្ជ្រៀវជាដើម ។ កិ. វិ. កងរំពង, ខ្លាំង : *ផ្អើលឈូ* ។

**ឈូក** ន. ផលផ្កាជាតិផ្កាមួយ ដើមវែងមានបន្លា, ស្លឹកធំកាក, ផ្កាប្រើជាគ្រឿងបូជា, ក្រអៅនិងមើមៈប្រើជាអាហារបានច្រើនយ៉ាង, បុកគ្រងប្រោះយកម្សៅក៏បាន, ផ្លែប្រើជាអាហារតាមខ្ចីតាមចាស់, កើតក្នុងស្រះ, ត្រពាំង, បឹង តាយកើត ដុះសាយជាប់រហ័ស; ឈូកមានច្រើនប្រភេទ គឺ *ឈូកស, ឈូកក្រហម, ឈូកប្រាល* ជាដើម ។ ឈ្មោះស្រុកមួយក្នុងខេត្តកំពត: *ស្រុកឈូក* ។

**ឈូង** ន. ឈូងសមុទ្រ, ទន្លេ, ស្ទឹង បឹង ដែលជាច្រកជាកៀនចូលក្នុងប្រាំង : *ឈូងសមុទ្រ* ។ របស់ក៏ដែលចង្ក្រងទុកសម្រាប់កាន់បោះ ឬបោលក្នុងល្បែងឈូង : *បោះឈូង, បោលឈូង*; ល្បែងនុះឯងក៏ហៅថា *ឈូង* ដែរ : *លេងឈូង, រៀនឈូង* ។

**ឈូប** ឧ. សូរសំឡេងលាន់ឮឡើងព្រមគ្នាក្រោមដៃដែលលូកចាប់អ្វីមួយៈគេលេងជាល្បែង : *ឈូប ! ចាក់ឈូប !*

**ឈូឆរ** កិ. វិ. ច្រើនៗ : *មានមនុស្សទៅឈូឆរ, ផ្អើលឈូឆរ, ជួយឈឺឆ្អាលឈូឆរ* ។

**ឈូឈី** ន. ឈ្មោះសម្លទឹកខាប់មួយប្រភេទ ។

**ឈូស** កិ. (សំ. *ឈូស* "បៀតបៀន, ពិឃាត



ប្រហារ") ចាំង ឆ្វៀលដោយដែកឈូស : *ឈូសឈើ* ។ ច្រកកំសុលទំនងផង : *យកដីឈូសដី* ។ ន. គ្រឿងដែកមានផ្លែមានស្លាប សម្រាប់ឈូស : *ផ្លែដែកឈូស, ស្លាបដែកឈូស, សំលៀងដែកឈូស* ។

**ឈើ** ន. អនុជាតិឈ្មោះពួកមួយ មានច្រើនប្រភេទ ជាពួកឈើរឹង ដុះលូតលាស់អាស្រ័យឫសដែលចាក់ចុះក្រោមបឺតរសជាតិនៃដី ទុកដូចជាអាហារឲ្យចម្រើនលូតលាស់ឡើង ថែក សម្បកស្លឹក ផ្លែ, ជាធាតុមានប្រយោជន៍យ៉ាងធំដល់ពួកមនុស្ស ... ។

**ឈើកង់** ន. ឈើហុបមានបណ្ដោយប្រវែង ១ ម៉ែត្រ ទៅដល់ ៥ ម៉ែត្រ (ហៅតាមទម្លាប់ស្រុក) ។

**ឈើគូត** ន. ឈើឬឬស្សីសម្រាប់គូតអ៊ីវ មានសម្បុរ ហោតតិចតួចជាដើម ។

**ឈើកែវ** ន. ឈ្មោះឈើមួយប្រភេទមានសាច់រឹងស្អិត សម្បុរសស្រគៀងនឹងសាច់ក្ដុក ។

**ឈើខ្មៅ** ន. ឈ្មោះឈើមួយប្រភេទមានខ្លឹមខ្មៅរលើប ។

**ឈើគូស** ន. ប្រដាប់សម្រាប់គូសយកភ្លើង : *ឈើគូស ១ ហោ, ឈើគូស ១ ប្រអប់, ប្រអប់ឈើគូស, សម្បកឈើគូស*; (ហៅ *ដែកគូស* ក៏បាន; កាលពីក្នុងសម័យបុរាណ *ប្រើដែកកេះ*, ក្នុងសម័យសព្វថ្ងៃនេះ ក៏នៅមានប្រើខ្លះដែរ ព្រោះជារបស់អាចធ្វើកើតដោយងាយមិនបាច់ទិញ, សម្រាប់អ្នកក្រីក្រ) ។

**ឈើចាក់ធ្មេញ** ន. ចម្រៀកឈើតូចៗ សម្រាប់ចាក់ឆ្កឹះឲ្យអស់មន្ទិលដែលជាប់នៅចន្លោះធ្មេញ ។

**ឈើច្រត់** ន. ឈើមានចម្ងាយដែកឬស្លាកចាក់នៅគល់ ឬគ្មានចម្ងាយក៏បាន សម្រាប់កាន់ច្រត់ទប់កាយកាត; ក្នុងវិន័យខាងព្រះពុទ្ធសាសនា មានពុទ្ធានុញ្ញាតឲ្យប្រើបានចំពោះតែភិក្ខុមានជំងឺ ដែលខានកាន់ឈើច្រត់មិនអាចនឹងដើរបាន, ឯឈើច្រត់នោះយ៉ាងវែងបានត្រឹមតែប្រវែង ៤ ហត្ថ, ត្រូវឲ្យមានអនុញ្ញាតអំពីជំនុំសង្ឃផងទើបកាន់បាន ។

**ឈើប្រាន** ន. ឈើឬឬស្សីស្រួចខ្លី សម្រាប់ចុះដិកស្ល់ ដែលវែងឲ្យមុខមានដារស្ដៅតូចហើយស្រួចស្រួច (អ្នកស្រុកខ្លះហៅ *ឈើដូន*) ។

**ឈើជ្រែង** ន. ឈើសម្រាប់ទល់ជ្រែងឬឈើដែលទល់, ទប់, ជ្រែងរ៉ូវកុំឲ្យប្រេះកុំឲ្យរលំ ។

**ឈើឈ្នាន់** ន. ឈើសម្រាប់ជាន់ឲ្យបង្គួរបើកបិទ (គ្រឿងតម្បាញ) ។

**ឈើក្រង់** ន. សម្ដីក្លាយមកពីពាក្យ *ចក្រង្គ* (ម. គ. នោះ) ។ នុះឈប់សូវប្រើតទៅទៀត, គួរប្រើ *ចក្រង្គ* វិញ ។

**ឈើទាល** ន. ឈ្មោះឈើមួយប្រភេទមានជ័រសម្រាប់ធ្វើចន្លុះឬបោះ, ទឹក, ពារូកជាដើម; ឯខ្លឹមសម្រាប់ប្រើជាគ្រឿងទូសម្ភារៈផ្សេងៗ, ជាឈើមានប្រយោជន៍យ៉ាងសំខាន់ក្នុងកម្ពុជប្រទេស ។

**ឈើទាលត្រាញ់** ន. ឈើធំមួយប្រភេទ ច្រើនមានតែនៅក្នុងព្រៃជោះជិតភ្នំ ។ ឈ្មោះឈើតូចមួយប្រភេទទៀត ដើមមូលស្រលូនត្រង់ ដុះលើកោះគោក (អ្នកស្រុកខ្លះហៅ *ឈើបុកជាស*) ។

**ឈើបុក ឬ ឈើបុះ** ន. ឈើមូលចុងស្រួចសម្រាប់បុកឬបុះឲ្យមានជារណ្ដៅតូចៗ ហើយដាក់គ្រាប់ពោត, គ្រាប់សណ្ដែកជាដើម ។

**ឈើផ្ដោក** ន. ឈើឬឫស្សីវែងសម្រាប់សង្កត់ផ្ដោកកន្ទួយស្រូវឲ្យស្ងួលកាលបើគេដើម្បីឲ្យស្រួលប្រមូល ។

**ឈើភ្លើង** ន. ឈ្មោះឈើមួយប្រភេទមានជាតុជ្រៃច្រើន, គេប្រើធ្វើជាឆ្នាំងកែក ។

**ឈើរ** ន. ឈើដែលចងបញ្ឈរភ្ជាក់កន្លះ (គ្រឿងកម្សាន្ត) ។

**ឈើរែត** ន. ឈើដែលចងពីចុងកំពងភ្ជាប់នឹងជ្រោះកញ្ចារ សម្រាប់រែតនូវរបស់ផ្សេងៗ ។

**ឈើស្ទូល** ន. (ព. ស្ទូល) ឈើស្រួចសម្រាប់ដាក់ក្រោមស្លឹកជាតំប្រឡៀបប្រមូលសាកសព ដែលធ្វើឈាបនកិច្ច ឲ្យស្រួលដាច់នេះស្រុល (ហៅតាមទម្លាប់ស្រុកថា ឈើស្ទូល (ស្ទូ) ក៏បាន) ។

**ឈើស្លឹង** (ស្លឹង-ង) ន. ឈើសម្រាប់សង្កត់សំពត់ គ្រឿងប៉ាក់ជាដើម ។

**ឈើស្នូន** ន. កំណាត់ឈើកឈើឬឫស្សីស្រស់ជាដើម សម្រាប់ទំពាដុសធ្មេញប្រះធ្មេញ (ហៅត្រឹមតែ ស្នូន ក៏បាន) ។

**ឈើស្រួច** ន. ឈើឬឫស្សីដែលគេចិតសម្រួចសម្រាប់ក្រសៀកកណ្ដាលឬក្ដួលជាដើមហើយដោតខ្លួន ។

**ឈើហុប** ន. ឈើមានទំហំដែលគេចាំងជា ៤ ជ្រុង ឬសាច់ចែកជា ៤ ជ្រុង (ហៅត្រឹមតែ ហុប ក៏បាន) ។

**ឈើអណ្ដាក** ន. ឈើស្រួចច្រើនរកុម សម្រាប់ដោតពីឃាតមនុស្សដែលមានទោសដល់ប្រហារជីវិត (មានតែក្នុងសម័យបុរាណកាលប៉ុណ្ណោះជាដើម) ។

**ឈើអន្លង** ន. ឈើសម្រាប់អន្លងស្បូវប្រឆ្នុំនោះ ។

**ឈើអែម** ន. ឈ្មោះឈើផ្លូវស្លឹះដើមតូច សំបកមានរសផ្អែម សម្រាប់ប្រើជាថ្នាំកែគោឬផ្សំធ្វើជាថ្នាំ ។

**ឈែល ១** គិ. ឬ កិ. វិ. គន្ធពន្លល (ត. អា.) ។

**ឈែល ២** ន. ចំពើដែលធ្វើឈែល (ត. អា.)

ឧ. ពាក្យអាសគ្រាមដែលអ្នកប្រយុទ្ធស្រែកលាន់ ... ពេលសំដៅទៅរកចំពើ ... នោះ ។

**ឈោង** គិ. លូកដៃយកទាំងខ្លួន : *ឈោងដៃចាប់, ឈោងដៃបេះផ្កា* ។

**ឈ្ងប់** គុ. ឬ កិ. វិ. ដែលមានក្លិនក្រអូបតិចៗ ; *ក្រអូបឈ្ងប់, ធុំឈ្ងប់* ។ *ឈ្ងុយឈ្ងប់* ឈ្ងុយខ្លាំង ។

**ឈ្ងប់ឈ្ងុយ ឬ ឈ្ងិតឈ្ងុយ** គិ. ឬ កិ. វិ. ស្ងៀមស្ងាត់, ស្ងៀមស្ងាត់, តិចតួចពិច : *ធ្វើការឈ្ងប់ឈ្ងុយ ឬ ធ្វើការឈ្ងិតឈ្ងុយ* ។

**ឈ្ងុយ** គុ. ឬ កិ. វិ. មានក្លិនធុំក្រអូបពិដោរដូចក្លិនស្លឹក, ផ្កា, ធ្វើរ, អង្ករ ដល់ទៀតសម្រាប់ភ្នាត : *ក្លិនឈ្ងុយ, ធុំឈ្ងុយ, ស្រោយក្លិនឈ្ងុយ* ។



**ឈ្ងៀម** គុ. ឬ កិ. វិ. មានក្លិនធុំស្រួយពិដោរ ដែលឆេះ : *ក្លិនឈ្ងៀម, ធុំឈ្ងៀម* ។

**ឈ្ងោក** គិ. បន្ទោន, បន្ទោរក្បាលទាំងខ្លួនទៅមុខ : *ឈ្ងោកកាយបង្គំ, ឈ្ងោកមើលមុខ* ។

**ឈ្នក់** ន. ប្រដាប់នេសាទមច្ឆជាតិមួយប្រភេទ មានសណ្ឋានដូចជ្រូង មានចំពាស់ ៤ មានជើង ១ ។

**ឈ្នាង** ន. ឈ្មោះប្រដាប់នេសាទមច្ឆជាតិ; ឈ្នាងមានបីប្រភេទគឺ *ឈ្នាងវែង* ធ្វើដោយបន្ទោះឫស្សី មានជើង ១ មានកាំផងសម្រាប់ជួសផងកោយត្រីនៅទឹកជ្រៅ, ទឹកហូរ; *ឈ្នាងដៃ* ឬ *ឈ្នាងផ្ទាត់* ធ្វើដោយបន្ទោះឫស្សីសម្រាប់ជួសកោយ (ផ្ទាត់) យកមច្ឆជាតិតូចៗ; *ឈ្នាងក្រាំ* ធ្វើដោយដោតឫស្សី មានជើង ២ មានកាំផងសម្រាប់ជួសចាញលើកបាន ប្រើការដាក់ក្រាំក្នុងទឹក ។

**ឈ្នាន់** ន. ប្រដាប់សម្រាប់ជាន់, សម្រាប់ទ្រជើង : *ឈ្នាន់កែបសេះ, ឈ្នាន់គោចក្រយាន* ។

**ឈ្នានីស ១** គិ. ប្រកែក ឬស្បា ចង្អាត កាត់ណាភកាត់ប្រយោជន៍គេ : *កុំឈ្នានីសគេ* ។

**ឈ្នានីស ២** ន. អំពើប្រកែក ឬស្បា កាត់ណាភកាត់ប្រយោជន៍គេ : *ឈ្នានីសជាអំពើទុច្ចរិត* ។

**ឈ្នុល** ន. មុខចំណាកកប់បន្ទោះកន្ទុល : *ឈ្នុលកន្ទុល* ។ ប្រដាប់ធ្វើដោយឫស្សីសម្រាប់ទាក់ខ្សែចងមង, ចង សំណាញ់ : *ឈ្នុលមង, ឈ្នុលសំណាញ់* ។

**ឈ្នុលតង្គ** ន. ប្រដាប់ធ្វើដោយឈើ មានសណ្ឋានដមស់ប៉ែតក់ពុងកណ្ដាល សម្រាប់ផ្ការតម្បាញ ។

**ឈ្នួត** ន. សំពត់សម្រាប់ជូត : *ជូលកន្សែងក្រមារ ក្រវាត់ឈ្នួតក្បាលពេញ* ។

**ឈ្នួល** ន. ថ្លៃដែលជួល; មនុស្សដែលជួលមកប្រើ : *គេយកឈ្នួល ៦០រៀលក្នុងមួយខែ; កេឈ្នួលឲ្យបានពីនាក់* ។

**ឈ្នៀង** ន. សំយាបដែលគត់គេហត្ថានេះញមកជារបៀង ។ ច្រើនថា *ឆ្នៀង* ក៏មាន ។

**ឈ្នះ** គិ. មានជ័យ, ប្រកបបានពីលើគេ : *ឈ្នះក្ដី, ឈ្នះសត្រូវ, ឈ្នះល្បែង* ។

**ឈ្នះឈ្នាន** គុ. ឥឡើង, ឈ្នានីស, ឥតកោតញញើត : *ក្មេងម្នាក់នេះឈ្នះឈ្នានណាស់* ។

**ឈ្នង** គុ. ល្អដោយមានសោភ័ណភាពញញឹមខ្លួន, បំព្រង : *មុខឈ្នង, កឈ្នង* ។

**ឈ្មុល** *កិ.* ម្មុលចូល, ស្រុកចូល, ឈ្មៀតចូល, លុកចូល : *ទោះបើទីចង្អៀតយ៉ាងណា ក៏ចេះតែឈ្មុលចូលមកដល់តែបាន* ។

**ឈ្មុស** ១ *ន.* សត្វជើង ៤ ពួកសំពោច មានទឹកសុក្កៈ ឬទឹកកាម ក្លិនប្រហើរ គេយកសម្រាប់លាយផ្សំធ្វើទឹកអប់ៈ ឈ្មុសមានពីរប្រភេទគឺ *ឈ្មុសស្បូវ* ១ ប្រភេទ *ឈ្មុសប្រែង* ១ ប្រភេទ; ឈ្មុសប្រែងនេះហៅថា *ឈ្មុសទេស* ក៏បាន, ឈ្មុសនេះឯងដែលគេយកទឹកកាមធ្វើទឹកអប់ ។

**ឈ្មុស** ២ *កិ.* ឈ្ងុយពាសពេញដោយក្រអូប : *ផ្កាឈ្មុសឈី, ផ្កាឈ្មុសពេញខ្យល់* ។

**ឈ្មុសទេស** *ន.* ឈ្មោះគ្រឿងក្រអូបម្យ៉ាងដែលធ្វើអំពីទឹកសុក្កៈឬទឹកកាមឈ្មុសទេស ។

**ឈ្មួញ** *ន.* អ្នកដែលធ្វើជំនួញ, អ្នកជួញ ។

**ឈ្មួយ** *ន.* អ្នកខ្ចី, អ្នកធ្វើការជាជំនួយ (មិនសូវប្រើ) ។

**ឈ្មៀត** *កិ.* ច្រៀត, ច្រកចូលទៅក្នុងចន្លោះ : *កណ្ដុរឈ្មៀតចូលតាមប្រហោងជញ្ជាំងផ្ទះ* ។

**ឈ្មែ** *ន.* ឈ្មោះត្រសក់ស្រូវម្យ៉ាង ផ្លែតូច ពុំឯង មិនជាប់ជាំ : *ត្រសក់ឈ្មែ* ។

**ឈ្មោល** *គុ.* ដែលមានភេទជាប្រុស; និយាយតែពីសត្វតិរច្ឆាន និងដើមឈើខ្លះ : *គោឈ្មោល, សេះឈ្មោល; ជ្រូកឈ្មោល, ល្ហុងឈ្មោល* ។ ត. ន្ទ. *ញី* ។

**ឈ្មោះ** *ន.* នាមពាក្យដែលសន្មតសម្រាប់ហៅមនុស្ស, សត្វ, ទី, របស់ផ្សេងៗ ។

**ឈ្មក់** ១ *ឧ.* ពាក្យបរិភាសសម្រាប់និយាយផ្សំនឹងពាក្យ ឈ្មី : *ឈ្មក់ឈ្មី* ឬ *ឈ្មីឈ្មក់* គឺច្របាច់ច្របល់, ទក់ទី ។

**ឈ្មក់** ២ *គុ.* ស្មុះពន្លិចដោយចូលចំហាយ, ដោយទឹក : *ឈ្មក់ផ្សែង, ឈ្មក់ម្ទេស, ឈ្មក់ទឹក* ។

**ឈ្មប** *កិ.* លបមើលដោយសម្ងាត់, លបស្ដាប់ ។

**ឈ្មប់** *គុ.* ពាក្យសម្រាប់ដាក់ពាក្យដែលឲ្យស្រពាប់ប្រគី : *ងងឹតឈ្មប់* គឺងងឹតមើលមិនច្បាស់ ។

**ឈ្មម** *គុ.* (ម. ព. *ជ្រលម*) ។

**ឈ្មានពាន** *គុ.* ដែលមានអាការចចើង, រលោភលន់, ប៉ានលើ : *មនុស្សឈ្មានពាន, សត្វឈ្មានពាន, កំពើឈ្មានពាន* ។

**ឈ្មាស** *គុ.* ប៉ិន, ប្រសប់, ស្ទាត់ : *ក្រាញ់ឈ្មាស, គំនិតឈ្មាស, មនុស្សឈ្មាស* ។ *ឈ្មាសវៃ* ប៉ិនរហ័ស, វាងវៃ (ប្រើជា *ឆ្លាត, ឆ្លាស* ក៏បាន) ។

**ឈ្មី** *កិ.* ច្របល់ដោយដៃជាដើម ។ *ឈ្មីឈ្មក់* (ម. ព. *ឈ្មក់* ១ ឧ.) ។



**ឈ្មឹក** *ន.* ឈ្មោះដើមឈើមួយប្រភេទ មានទំហំល្មម ក្រពើ ប្រើធ្វើជាសសរផ្ទះបាន ។

**ឈ្មូស** *ន.* សត្វម្រឹគមួយប្រភេទសណ្ឋាននឹងប្ដាត់ ។

**ឈ្មើង** *ន.* សត្វទឹកតូចល្អិត ស្រែកស្ទើរតែកើតនៅតាមពពុះ អណ្ដែតឈាមមនុស្ស, សត្វ; ឈ្មើងមានច្រើនប្រភេទមាន *ឈ្មើងគង្វាស* គឺឈ្មើងតូចៗ និង *ឈ្មើងព្រៃ* គឺឈ្មើងធំៗជាដើម ។ *ឈ្មើងសមុទ្រ* ឈ្មើងធំៗមានសាច់ក្រាស់ គេប្រើជាភេសជ្ជៈបាន ។

**ឈ្មើយ** ១ *ន.* ឬ *គុ.* មនុស្សដែលគេចាប់បាននៅក្នុងចំពាំង ឬសត្វដែលគេចាប់បាននៅក្នុងព្រៃដោយមានខ្នាក់ ។

**ឈ្មើយ** ២ *គុ.* ដែលមានអាការព្រៃ, ខ្លាំង : *សម្ដីឈ្មើយ, មុខឈ្មើយ* ។

**ឈ្មៀស** *កិ.* ស្ពាន់កែងបោកពោះៈឬយកមនុស្សមកប្រើជាកងការបណ្ដើរសឹក ដោយបង្ខំការប្រញាប់ប្រញាប់ : *ឈ្មៀសរទេះ, ឈ្មៀសគោ, ឈ្មៀសមនុស្ស* ។

**ឈ្មោច** *កិ.* ចាប់ក្រវាត់ដើម្បីឲ្យបែក, ខ្ទះស្លៀង, ខ្ទេចខ្ទី, ខ្សែក្រោម (ភ្លេច) ។ *ឈ្មោចឈ្មី* ឈ្មោចហើយឈ្មីផង ។ ព. ប្រ. សង្កត់សង្កិន, ញាំញីឥតប្រណី ។ *ឈ្មោចស្ងួត* ជជីកសួរសង្កត់ ដោយអាការចូលចោះចំរឿង, ចំហេតុ ។

**ឈ្មោម** *គុ.* ដែលឥតមានសម្បុរៈ*សម្បុរឈ្មោម* ។

**ឈ្មោម** *គុ.* សេម, ស្រួចណាស់ : *ចុងកាំបិតស្រួចឈ្មោម* ។

**ឈ្មោះ** *កិ.* និយាយប្រកែកតបតវ៉ាពាក្យផុសៗទៅវិញទៅមកដោយកំហឹង ។

**ឈ្មាត** *ន.* ឈ្មោះត្រីគល់មួយប្រភេទ មានច្រមុះស្វាយស្ទួចក្នុងត្រីប្រា : *ត្រីឈ្មាត* ។

**ឈ្មោង** *គុ.* ថ្លាជ្រះដដែលថ្លុល : *វិញ្ញាណឈ្មោង* ។ ម. ព. *ទន់, វង់* ឬ *ហង់* ទៀតផង ។

**ឈ្មោងយល់** *កិ.* ដឹងគិតយល់ដោយប្រាជ្ញាជ្រាលជ្រៅ ។

**ឈ្មាំង** *ន.* ឈ្មោះផ្ដៅមួយប្រភេទ មានសាច់ដែលជាប់ជាងផ្ដៅឯទៀត : *ផ្ដៅឈ្មាំង* ។